ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៨ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការព័ត៌មានស្ថិតិទីផ្សារការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ១១៧អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការប្រមូល និងចងក្រង ព័ត៌មានទីផ្សារការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីជូនដំណឹងលេខ៥២៨ សជណ សរ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត "**គណៈកម្មការព័ត៌មានស្ថិតិទីផ្សារការងារ**" ដើម្បីដឹកនាំ និងសម្របសម្រួលការអនុវត្ត ប្រមូល វិភាគ និងផ្សព្វផ្សាយស្ថិតិផ្លូវការដែលបានចាត់តាំងស្តីពីព័ត៌មានស្ថិតិទីផ្សារការងារកម្ពុជា ដូចដែលបានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានឱ្យបានទាន់ពេលវេលា ប្រកបដោយភាពជាក់លាក់ អាចជឿទុកចិត្តបាន ឆ្លើយតបទៅនឹងការប្រែប្រួលក្នុងទីផ្សារការងារកម្ពុជា ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។

**ប្រការ២ .-**

គណៈកម្មការមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៥- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៦- អគ្គលេខាធិការនៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា | សមាជិក |
| ១៧- តំណាងវិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ១៨- អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩- អគ្គនាយកការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២០- អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២១- ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ២២- នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ២៣- ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត | សមាជិក |
| ២៤- តំណាងនិយោជក | សមាជិក។ |

**ប្រការ៣ .–**

សមាសភាពជាក់ស្តែងនៃគណៈកម្មការត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការ។

**ប្រការ៤ .–**

គណៈកម្មការព័ត៌មានស្ថិតិទីផ្សារការងារមានភារកិច្ចៈ

- ដឹកនាំ រៀបចំផែនការការងារក្នុងការប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយព័ត៌មានស្ថិតិទីផ្សារការងារកម្ពុជា ដោយសម្របសម្រួលរួមបញ្ចូលគ្នានូវផែនការសកម្មភាពរបស់អង្គភាពស្ថិតិដែលបានចាត់តាំងទទួលបន្ទុកផ្នែកព័ត៌មានទីផ្សារការងារ ផ្នែកស្ថិតិការងារ ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងផ្នែកបេឡាជាតិរបបសន្តិសុខសង្គម។
- ដឹកនាំ សម្របសម្រួលការអនុវត្តកាតព្វកិច្ចរដ្ឋបាល និងលើកកម្ពស់កិច្ចសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក្នុងការផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធជូនអង្គភាពស្ថិតិដែលបានចាត់តាំងទទួលបន្ទុកផ្នែកព័ត៌មានទីផ្សារការងារ ផ្នែកស្ថិតិការងារ ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងផ្នែកបេឡាជាតិរបបសន្តិសុខសង្គម។
- ដឹកនាំការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលតម្រូវឱ្យសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ក្រុមហ៊ុន សហគ្រាសឯកជននិងសាធារណៈ និងនិយោជកផ្សេងៗទៀតដែលមានកាតព្វកិច្ចក្នុងការផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យពាក់ព័ន្ធព័ត៌មានស្ថិតិទីផ្សារការងារ និងរបាយការណ៍អំពីតម្រូវការកម្លាំងពលកម្ម ជំនាញ មុខរបរ និងការប្រែប្រួលចំនួនបុគ្គលិកឱ្យបានទៀងទាត់ និងទាន់ពេលវេលាជូនអង្គភាពស្ថិតិដែលបានចាត់តាំងទទួលបន្ទុកផ្នែកព័ត៌មានទីផ្សារការងារ ផ្នែកស្ថិតិការងារ ផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងផ្នែកបេឡាជាតិរបបសន្តិសុខសង្គម។
- ដឹកនាំការប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយ ឱ្យបានទៀងទាត់ និងទាន់ពេលវេលានូវព័ត៌មានស្ថិតិទីផ្សារការងារស្តីពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ជំនាញ និងមុខរបរប្រកបដោយភាពជាក់លាក់ និងអាចទុកចិត្តបានដែលមានប្រភពមកពីៈ
  + ទិន្នន័យ ព័ត៌មាន និងកំណត់ត្រារដ្ឋបាល ដែលត្រូវបានប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំង និងកំណត់ត្រារដ្ឋបាលដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា។
  + ការអង្កេត និងទិន្នន័យ ដែលត្រូវបានប្រមូល វិភាគ និងផ្សព្វផ្សាយដោយប្រភពស្ថិតិផ្សេងៗ។
- ដឹកនាំការសិក្សាស្រាវជ្រាវ វិភាគ ប៉ាន់ស្មាន និងព្យាករណ៍ព័ត៌មានស្ថិតិទីផ្សារការងារកម្ពុជា។
- កៀរគរធនធានទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីគ្រប់ប្រភពសម្រាប់គាំទ្រការប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយព័ត៌មានស្ថិតិទីផ្សារការងារកម្ពុជា។
- បំពេញភារកិច្ចចាំបាច់ផ្សេងទៀតពាក់ព័ន្ធការប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មានស្ថិតិទីផ្សារការងារនៅកម្ពុជា។

**ប្រការ៥ .–**

គណៈកម្មការនេះ មានលេខាធិការដ្ឋានមួយដែលស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាសេនាធិការ។

**ប្រការ៦ .-**

គណៈកម្មការនេះ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិការដ្ឋ ជាកញ្ចប់ថវិកាដាច់ដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងៗទៀត សម្រាប់ចំណាយលើការប្រមូល ចងក្រង វិភាគទិន្នន័យ និងព័ត៌មាន ការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់បម្រើសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សម្ភារ បរិក្ខារ និងការឧបត្ថម្ភផ្សេងៗតាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

**ប្រការ៧ .-**

គណៈកម្មការនេះ អាចប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងការបំពេញការងារ។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ